**ព្រះរាជសារ**
**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ**
**ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល**
**ក្នុងឱកាសអបអរសាទរខួបលើកទី១០៧**
**នៃទិវាអន្តរជាតិ នារី ៨មីនា ឆ្នាំ២០១៨**

៙៙៙★៚៚៚

សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា និងជាទីនឹករលឹកដ៏ជ្រាលជ្រៅបំផុត!

នៅក្នុងឱកាសដ៏មហាប្រសើរនៃការរំលឹកខួបលើកទី១០៧ ទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០១៨ នេះ ខ្ញុំ សូមចូលរួមអបអរសាទរជាមួយបងប្អូន ជនរួមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជាយើង ដោយក្តីសោមនស្សរីករាយក្រៃលែង។

ខ្ញុំ សូមជម្រាបសួរសុខទុក្ខ និងសូមផ្ញើនូវក្តីនឹករលឹកដ៏កក់ក្តៅដល់បងប្អូន កូនចៅ ចៅទួត ទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជានិច្ចកាលតែងតែផ្តល់នូវការគាំទ្រ គោរព ស្រឡាញ់ ភក្តីភាពនឹករលឹកដល់ **ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងបានសំដែងនូវក្តីកតញ្ញូមិនអាចកាត់ថ្លៃបានថ្វាយ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ដែលធ្វើឱ្យយើងខ្ញុំ ចងចាំជានិច្ច។

បងប្អូន កូនចៅ ចៅទួតជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ ទិវាអន្តរជាតិនារី ៨មីនា ជាទិវាសកលមួយ ដែលរំលឹកអំពីវីរភាពនៃការតស៊ូរបស់នារីនៅទូទាំងសកលលោក ដើម្បីទាមទារឱ្យមានការលើកកម្ពស់ស្ថានភាព ជីវភាព សិទ្ធិសេរីភាព ឋានៈតួនាទីរបស់ស្ត្រីនៅក្នុងសង្គម។ ហេតុនេះ បានជារៀងរាល់ឆ្នាំប្រទេសនីមួយៗ តែងតែលើកយកប្រធានបទទាក់ទិននឹងស្ត្រី ដើម្បីអបអរសាទរ ដាក់ចេញជាសកម្មភាព ឱ្យស្របទៅនឹងបរិការណ៍របស់ប្រទេសរៀងៗខ្លួន។ ដោយឡែកសម្រាប់ព្រះរាជាណាចក្រកម្ពុជាយើងនៅឆ្នាំនេះ ក៏បានលើកយកប្រធានបទ ស្តីពី "**ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ**" ដែលជាប្រធានបទមានសារៈសំខាន់ណាស់ ។

ខ្ញុំ សូមគាំទ្រប្រធានបទឆ្នាំនេះ ស្តីពី "**ស្ត្រីរួមគ្នារក្សាសន្តិភាព ដើម្បីអភិវឌ្ឍន៍ជាតិ**" ដែលបានធ្វើឱ្យយើងនឹកឃើញឡើងវិញពីសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជបូជនីយកិច្ចដឹកនាំដ៏ឧត្តុង្គឧត្តម និងប្រកបដោយព្រះបញ្ញាញាណដ៏ឈ្លាសវៃនៃ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ សម្តេចឪ សម្តេចតា សម្តេចតាទួត** ដែលព្រះរាជាណាចក្រកម្ពុជា មានសុខសន្តិភាព ឯករាជ្យ សម្បូររុងរឿងប្រកបដោយកិត្តិយស

កិត្តិស័ព្ទល្បីល្បាញពេញតំបន់ និងនៅក្នុងពិភពលោក។ តែជាអកុសល ក្រោយឆ្នាំ១៩៧០ កម្ពុជាយើងត្រូវទទួលរងនូវសង្គ្រាមដ៏រ៉ាំរ៉ៃអស់រយៈកាលជាច្រើនឆ្នាំ និងបានបន្សល់ទុកនូវស្ត្រីមេម៉ាយ កុមារកំព្រាគ្មានទីពឹង ព្រមទាំងធ្វើឱ្យប្រទេសជាតិត្រូវបានបំផ្លិចបំផ្លាញខ្ទេចខ្ទី។ ក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩ សន្តិភាពក៏ចាប់ផ្តើមមានឡើងវិញ ដោយមានកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលនាំឱ្យមានការបោះឆ្នោតនៅឆ្នាំ១៩៩៣ ហើយទទួលបានសន្តិភាពពេញលេញនៅឆ្នាំ១៩៩៨ តាមរយៈការដាក់ចេញនូវគោលនយោបាយ ផ្តួចផ្តើមដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលជាប្រមុខដឹកនាំប្រកបដោយគតិបណ្ឌិត។

ដោយសារមានសន្តិភាពពេញលេញ ប្រជារាស្ត្រខ្មែរបានទទួលនូវភាពសុខសាន្តនៅទូទាំងប្រទេស និងទទួលបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧ភាគរយ ប្រកបដោយចីរភាព តាមរយៈកិច្ចខិតខំប្រឹងប្រែងការអនុវត្តប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនូវយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។ ប្រជាពលរដ្ឋគ្រប់រូប ជាពិសេសស្ត្រីមានឱកាសសិក្សារៀនសូត្រ បង្កើនចំណេះដឹងនិងជំនាញជ្រៅជ្រះ សម្រាប់យកទៅប្រកបការងារ និងមានមុខរបរបង្កើនប្រាក់ចំណូលសម្រាប់គ្រួសារ និងសេដ្ឋកិច្ចជាតិ។

ឆ្លៀតក្នុងឱកាសអបអរសាទរ ទិវាអន្តរជាតិនារី ៨មីនានេះ ខ្ញុំ សូមកូនចៅជាមាតាបិតាទាំងអស់ប្រឹងប្រែងលើកកម្ពស់សីលធម៌ វប្បធម៌អហិង្សា នៅក្នុងគ្រួសារតាមរយៈការអប់រំទូន្មានប្រៀនប្រដៅកូនចៅ សាច់ញាតិឱ្យក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ ជៀសឆ្ងាយពីគ្រឿងញៀន គ្រឿងស្រវឹង ការប្រើអំពើហិង្សា ដោយត្រូវប្រកាន់យកនូវសីលធម៌ សុជីវធម៌ និងរួមចំណែករក្សាការពារសន្តិភាព សណ្តាប់ធ្នាប់ល្អ ដើម្បីរស់នៅក្នុងសង្គមមួយប្រកបដោយភាពថ្លៃថ្នូរ សម្បូរសប្បាយ និងសុខដុមរមនាជារៀងរហូត។ យើងត្រូវរួបរួមសាមគ្គីជាធ្លុងមួយ តាមព្រះរាជបណ្តាំរបស់ **ព្រះករុណា ព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ**។

នៅក្នុងឱកាសដ៏ឧត្តុងឧត្តមនេះ ខ្ញុំ សូមសំដែងនូវការកោតសរសើរជាថ្មីម្តងទៀត ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអ្នកឈានមុខ ក្នុងការខិតខំប្រឹងប្រែង នាំមកនូវសន្តិភាពពេញលេញ ដើម្បីប្រជារាស្ត្រ និងមាតុភូមិកម្ពុជា។

ខ្ញុំ សូមកោតសរសើរដ៏កក់ក្តៅបំផុត **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** អ្នកដឹកនាំដ៏ឆ្នើម និងជាគំរូដ៏ល្អ ដែលបានលះបង់កម្លាំងកាយ-ចិត្ត ក្នុងសកម្មភាពរបស់កាកបាទក្រហមកម្ពុជា និងបានខិតខំពុះពារលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ឱ្យមានកិត្តិយស និងសេចក្តីថ្លៃថ្នូរក្នុងសង្គម។

ខ្ញុំ សូមសរសើរ និងគាំទ្រថ្នាក់ដឹកនាំ មន្ត្រីរាជការក្រសួងកិច្ចការនារី និងគ្រប់ក្រសួងស្ថាប័នផ្នែកឯកជន ដៃគូអភិវឌ្ឍន៍ ដែលបាននឹងកំពុងខិតខំប្រឹងប្រែងជំរុញការលើកកម្ពស់

សមភាពយេនឌ័រ ដើម្បីស្ត្រីបានទទួលកិច្ចការពារសិទ្ធិ និងផលប្រយោជន៍ តាមរយៈការជំរុញសមាជិកនៅក្នុងគ្រួសារឱ្យទទួលស្គាល់ និងចាត់ទុកស្ត្រីជាដៃគូដ៏សំខាន់ ក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។ ខ្ញុំ សូមគាំទ្រការផ្តល់កាលានុវត្តភាពឱ្យស្ត្រីបានកសាង និងអភិវឌ្ឍន៍សមត្ថភាព ក៏ដូចជាបានចូលរួមក្នុងគ្រប់ការងារ គ្រប់វិស័យប្រកបដោយសមធម៌។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្លែងអំណរព្រះគុណ សម្តេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមអរគុណដ៏ជ្រាលជ្រៅ បងប្អូនជនរួមជាតិ មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានបន្តការខិតខំប្រឹងប្រែង និងគាំទ្រ ការតស៊ូដ៏ស្វិតស្វាញរបស់ស្ត្រី ក្នុងតួនាទីជាសមាជិកដ៏មានតម្លៃសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចគ្រួសារ និងសង្គម។ ខ្ញុំ សង្ឃឹមថាកិច្ចខិតខំប្រឹងប្រែងនេះនឹងមានជាបន្តទៅទៀតជារៀងរហូត។

ខ្ញុំម្ចាស់ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយ-ប្រគេនព្រះពរ សម្តេចព្រះមហាសង្ឃរាជ ព្រះរាជាគណៈ ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមប្រសិទ្ធពរជ័យ សិរីមង្គលមហាប្រសើរ ជូនចំពោះថ្នាក់ដឹកនាំនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ មន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍វិស័យឯកជន ព្រមទាំងបងប្អូនជនរួមជាតិនៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងនារីទូទាំងសកលលោក សូមប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ និងបានប្រកបតែនឹងសុភមង្គល សុខភាពល្អបរិបូរណ៍ អាយុយឺនយូរជាដរាប។

សូមអរព្រះគុណ សូមអរគុណ